# “ការបូមបេតុង”

## ចំណុចសំខាន់សម្រាប់សុវត្ថិភាពនិងសុខភាព

# បម្រុងប្រយ័ត្នចំពោះការងាររៀបចំ

## (1) សមត្ថភាពចាំបាច់សម្រាប់ការបូមបេតុង

- អ្នកដែលពាក់ព័ន្ធនឹងការងារបូមបេតុងត្រូវតែបានបញ្ចប់ការបណ្តុះបណ្តាលពិសេសដែលអនុលោមតាមច្បាប់សុវត្ថិភាពឧស្សាហកម្មនិងសុខភាព។




ឧទាហរណ៍អំពីវិញ្ញាបនបត្របញ្ជាក់ការបណ្តុះបណ្តាលពិសេសស្តីពីរថយន្តបូមបេតុង

## (3) ការពិនិត្យមើលសម្លៀកបំពាក់និងឧបករណ៍សុវត្ថិភាព

- ចូរប្រាកដថាបានពាក់សម្លៀកបំពាក់, ឧបករណ៍ការពារសុវត្ថិភាព (មួកសុវត្ថិភាព, ប្រព័ន្ធបង្ការការធ្លាក់, ស្បែកជើងសុវត្ថិភាព។ល។) បានត្រឹមត្រូវ។




ការពិនិត្យសម្លៀកបំពាក់និងគ្រឿងបរិក្ខារការពារសុវត្ថិភាព

## (3) ការជ្រើសរើសបំពង់បូមនិងគ្រឿងបរិក្ខារ

ត្រូវតែត្រួតពិនិត្យនិងជ្រើសរើសយកបំពង់បញ្ជូននិងគ្រឿងបរិក្ខារដែលមិនសឹករេចរិល ឬខូចខាត។ ការប្រើបំពង់បញ្ជូនដែលខូច ឬស្តើងពេក អាចបណ្តាលឲ្យមានគ្រោះថ្នាក់ផ្ទុះអំឡុងពេលប្រតិបត្តិការបូម។



ការជ្រើសរើសបំពង់បញ្ជូន



ឧទាហរណ៍អំពីគ្រោះថ្នាក់ធ្លាយបំពង់បញ្ជូន

## (4) ការត្រួតពិនិត្យឧបករណ៍បង្ការជើងជ្រែងកុំឲ្យលៀនចេញ

មុននឹងដំណើរការរថយន្តបូមបេតុង ចូរប្រាកដថាបានបង្រួមជើងជ្រែងចូលអស់ និងបំពាក់ឧបករណ៍បង្ការការលៀនចេញយ៉ាងគត់មត់។



ការពិនិត្យឧបករណ៍បង្ការជើងជ្រែងកុំឲ្យលៀនចេញ




កន្លាស់ស៊កខ្ទាស់ជើងជ្រែងនិងឧទាហរណ៍ពីច្រវាក់ការពារការលៀនចេញ

## (5) បម្រុងប្រយ័ត្នចំពោះសកម្មភាពនៅលើគ្រឿងចក្របូមបេតុង (1)

អាចមានគ្រោះថ្នាក់ធ្លាក់ពីលើរថយន្តបូមបេតុងនៅពេលផ្ទុកគ្រឿងបរិក្ខារ និងប្តូរបំពង់បញ្ជូនរបស់ដងសន្ទូចនៅលើគ្រឿងចក្រ។ ចាត់វិធានការបង្ការដូចជាដាក់កម្រាលបំពេញការងារ។ល។ដើម្បីបង្ការការធ្លាក់។



ឧទាហរណ៍ពីគ្រោះថ្នាក់ធ្លាក់ពីផ្នែកខាងលើរថយន្តបូមបេតុង

## (6) បម្រុងប្រយ័ត្នចំពោះសកម្មភាពនៅលើគ្រឿងចក្របូមបេតុង (2)

អាចមានគ្រោះថ្នាក់ដោយសារដងសន្ទូចធ្លាក់ចុះហើយគាបមនុស្សជាប់នៅចន្លោះដងសន្ទូច និងតួរថយន្ត។ ចាត់វិធានការបង្ការគ្រោះថ្នាក់ដោយរំកិលដងសន្ទូចទៅចំហៀងតួរថយន្ត ឬប្រើជើងទម្រ។



ឧទាហរណ៍ពីគ្រោះថ្នាក់គាបជាប់ក្នុងដងសន្ទូចនៅលើរថយន្តបូមបេតុង

## (7) បម្រុងប្រយ័ត្ននៅពេលផ្ទុកនិងទម្លាក់គ្រឿងបរិក្ខារ

នៅពេលទម្លាក់បំពង់បូមនិងគ្រឿងបរិក្ខារចុះពីរថយន្តបូមបេតុង, ចូរប្រយ័ត្នរអិលធ្លាក់។ លើសពីនេះទៀត អាចមានគ្រោះថ្នាក់រងរបួសដល់ដៃនិងមេជើងដោយសារតែធ្លាក់វត្ថុធ្ងន់លើ នៅពេលផ្ទុកឬទម្លាក់វត្ថុធ្ងន់ដូចជាបំពង់បញ្ជូនជាដើម។ សូមទម្លាក់បំពង់បញ្ជូនចុះដោយប្រុងប្រយ័ត្ន ដោយហៅគ្នាពីរបីនាក់ឲ្យជួយ។



ឧទាហរណ៍អំពីគ្រោះថ្នាក់ធ្លាក់
នៅពេលទម្លាក់ទុយោចុះ



ឧទាហរណ៍អំពីគ្រោះថ្នាក់ដែលបំពង់បញ្ជូនធ្លាក់លើ
និងរងរបួសជើង

## (8) ការត្រួតពិនិត្យមុននឹងចាប់ផ្ដើមការងារ

ពេលមកដល់ការដ្ឋាន ចូរពិនិត្យមើលលក្ខខណ្ឌដែលការងារបូមបេតុងប្រចាំថ្ងៃអាចអនុវត្តដោយសុវត្ថិភាព។ ត្រូវតែត្រួតពិនិត្យវាមុននឹងចាប់ផ្ដើមការងារ។




ធ្វើការត្រួតពិនិត្យមុននឹងចាប់ផ្ដើមការងារ